# របាយការណ៍
# ស្តីពី
# លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈ ប្រចាំខែមេសា ឆ្នាំ២០១៤

## I. សេចក្តីផ្តើម ៖

អនុវត្តតាមកម្មវិធីនយោបាយ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៤ រយៈពេលមួយខែនេះ គ្រប់អង្គភាពចំណុះក្រសួងបានខិតខំប្រឹងប្រែងបង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ ជាពិសេសវិស័យឯកជនតាមគោលការណ៍របស់រាជរដ្ឋាភិបាលគឺ **រដ្ឋគាំទ្រ ដៃគូឯកជនជាអ្នកអនុវត្ត** ស្របតាមគោលនយោបាយ " **អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ** " ក្នុងគោលបំណងធ្វើឱ្យ " **វប្បធម៌ ក្លាយជាសេដ្ឋកិច្ចជាតិ**" ដោយជម្រុញបន្ថែមនូវការប្រើប្រាស់សក្តានុពលវប្បធម៌ជាតិជាថាមពលអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹងការបង្កបង្កើនផលិតផលឧស្សាហកម្មវប្បធម៌សម្រាប់គោលដៅពាណិជ្ជកម្ម និងទេសចរណ៍ ដោយបង្កើតការងារ ពង្រឹងសីលធម៌សង្គម និងរបៀបរស់នៅថ្លៃថ្នូរ ធ្វើឱ្យខ្មែរមានគំនិតបង្កបង្កើត និងបង្កើននិន្នាការស្នេហាវប្បធម៌ជាតិ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ធ្វើឱ្យសង្គមទទួលបាននូវសុខដុមរមនា ដើម្បីឈានទៅសម្រេចគោលដៅ "**កម្ពុជា ៖ ព្រះរាជាណាចក្រនៃវប្បធម៌**" ។

## II. រចនាសម្ព័ន្ធ និងក្របខណ្ឌ ៖

### ១.រចនាសម្ព័ន្ធ ៖

**ក-**<u>**ថ្នាក់ដឹកនាំក្រសួង ៖**</u>

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដឹកនាំដោយ **រដ្ឋមន្ត្រី១រូប** អមដោយ**រដ្ឋលេខាធិការ៧រូប** និង**អនុរដ្ឋលេខាធិការ៨រូប**។

**ខ-**<u>**ថ្នាក់រដ្ឋបាលកណ្តាល ៖**</u>

ថ្នាក់រដ្ឋបាលកណ្តាល ក្រសួងមាន ៖

**-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំនួន០៩** (នា.រដ្ឋបាល នា.បុគ្គលិក នា.ផែនការស្ថិតិ និងសរុប នា.គណនេយ្យ ហិរញ្ញវត្ថុ នា.សំភារៈ និងបរិក្ខារ នា.នីតិកម្ម នា.សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នា.សហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន សាលាបណ្តុះបណ្តាលក្របខណ្ឌវប្បធម៌) ។

**-អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មាននាយកដ្ឋានចំនួន០៥** (នា.អភិវឌ្ឍវប្បធម៌ នា.សៀវភៅការអាន នា.សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នា.សិល្បៈទស្សនីយភាព នា.សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម) ។

**-អគ្គនាយកដ្ឋានបេតិកភណ្ឌ មាននាយកដ្ឋានចំនួន០៤** (នា.បុរាណវត្ថុ នា.សារមន្ទីរ នា.បុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នា.គាំពារ និងអភិរក្សសំណង់បុរាណ) ។

ក្រៅពីនេះនៅមានអង្គភាពចំនួន០៤ទៀត ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រី ៖

**-សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលជាគ្រឹះស្ថានសាធារណៈ ថ្នាក់ស្មើអគ្គនាយកដ្ឋាន** មានមហាវិទ្យាល័យចំនួន០៥ (មហា.បុរាណវិទ្យា មហា.ស្ថាបត្យកម្ម និងនគរូបនីយវិទ្យា មហា.សិល្បៈសូនរូប មហា.តូរ្យតន្ត្រី មហា.នាដសាស្ត្រ) និង មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ១ ។

**-នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**-អធិការដ្ឋាន ថ្នាក់ស្មើនាយកដ្ឋាន**

**-សាលាមធ្យមវិចិត្រសិល្បៈ** ថ្នាក់ស្មើនាយកដ្ឋាន មានសាលាជំនាញចំនួន០៥ (សាលារបាំ សាលាសៀក សាលាសិល្បៈសូនរូប សាលាតូរ្យតន្ត្រី សាលាល្ខោន) ។

**គ-ថ្នាក់រាជធានី-ខេត្ត ៖**

ក្រសួងមានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ចំនួន២៤ និងការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង ខណ្ឌ ស្រុក ចំនួន១៦៦ការិយាល័យ ។

## ២.ក្របខណ្ឌមន្ត្រីរាជការ ៖

ក្រសួងមានមន្ត្រីរាជការសរុបចំនួន**២.៥១៣នាក់** ក្នុងនោះស្រី**៨៤៨នាក់** ចែកចេញជា ៖-

-ថ្នាក់រដ្ឋបាលកណ្តាល មានចំនួន**១.៤៨២នាក់** ក្នុងនោះស្រី**៥៦៨នាក់**

-ថ្នាក់មន្ទីរវប្បធម៌រាជធានី-ខេត្ត មានចំនួន**១.០៣១នាក់** ក្នុងនោះស្រី**២៨០នាក់** ។

## III. សកម្មភាពការងារថ្នាក់ដឹកនាំក្រសួង ៖

### សកម្មភាពក្នុងប្រទេស ៖

-ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ **លោកជំទាវរដ្ឋមន្ត្រី** ទទួលជួប ឯកអគ្គរដ្ឋទូតរុស្ស៊ី ប្រចាំនៅកម្ពុជា ដើម្បីសម្តែងការគួរសម

-ថ្ងៃទី១៣-១៤ ខែមេសា ឆ្នាំ២០១៤ **លោកជំទាវរដ្ឋមន្ត្រី** បានចូលរួមជាគណៈអធិបតីក្នុងពិធីបើកអង្គរសង្ក្រាន និង អបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ នៅរមណីយដ្ឋានអង្គរ ខេត្តសៀមរាប

-ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ **លោកជំទាវរដ្ឋមន្ត្រី** ទទួលជួប ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប៉ូឡូញ ប្រចាំនៅកម្ពុជា ដើម្បីសម្តែងការគួរសម

-ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ **លោកជំទាវរដ្ឋមន្ត្រី** ទទួលជួប អង្គការអេម្រឹតា ដើម្បីសម្តែងការគួរសម

-ថ្ងៃទី២៣-២៦ ខែមេសា ឆ្នាំ២០១៤ ឯកឧត្តម ធៀង វណ្ណដារ៉ុង អនុរដ្ឋលេខាធិការ បានចុះទៅពិនិត្យការរៀបចំផ្តល់លិខិតអនុញ្ញាតនាំចេញវត្ថុសិល្បៈទៅក្រៅប្រទេស នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ។

**សកម្មភាពក្រៅប្រទេស ៖**

-ថ្ងៃទី១៥-២១ ខែមេសា ឆ្នាំ២០១៤ **លោកជំទាវរដ្ឋមន្ត្រី** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចំនួន០៤រូប ចូលរួមកិច្ចប្រជុំឧត្តមមន្ត្រី The 6th Meeting of ASEAN Ministers Responsible for Culture and Arts (AMCA) និង The 9th Meeting of Senior Officials Responsible for Culture and Arts (SOMCA) នៅប្រទេសវៀតណាម

-ថ្ងៃទី០៦-០៩ ខែមេសា ឆ្នាំ២០១៤ ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចំនួន០២រូប ចូលរួមកម្មវិធីឆ្នាំផ្លាស់ប្តូរវប្បធម៌អាស៊ាន-ចិន ២០១៤ " 2014 China-ASEAN Culture Exchange Year" នៅប្រទេសចិន ។

IV. **លទ្ធផលការងារ ៖**

## ១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ ៖

### ១.១.ការងាររដ្ឋបាលទូទៅ ៖

-បានទទួលលិខិតចូលពីគ្រប់ស្ថាប័នចំនួន២២៥ច្បាប់ និង បញ្ជូនលិខិតចេញទៅគ្រប់ស្ថាប័នចំនួន២៧៨ច្បាប់

-បានតាក់តែងនិពន្ធអត្ថបទលិខិតរដ្ឋបាល និងលិខិតបទដ្ឋានបានចំនួន២៥ច្បាប់ តាមតម្រូវការថ្នាក់ដឹកនាំ

-បានរៀបចំទទួលភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីប្រជុំផ្សេងៗបានទាន់ពេលវេលា

-កម្លាំងសន្តិសុខ និងនគរបាលយាមប្រចាំការពេលថ្ងៃ និងយប់សហការគ្នាបានល្អក្នុងការថែរក្សាសុវត្ថិភាព នៅទីស្តីការក្រសួង

-ផលិតលិខិតស្នាមផ្សេងៗជូនថ្នាក់ដឹកនាំក្រសួងស្របតាមតម្រូវការ ដោយបានបញ្ជូនចេញតាមរយៈច្រកចេញរដ្ឋបាលទៅគ្រប់គោលដៅ និងស្ថាប័នពាក់ព័ន្ធទាន់ពេលវេលាយ៉ាងរលូន

-បានធ្វើការចែកចាយសៀវភៅរាជកិច្ចជូនថ្នាក់ដឹកនាំ និងតាមអង្គភាពតាមគោលការណ៍ប្រចាំខែសរុបបានចំនួន៣៣០ក្បាល

-ការិយាល័យពត៌មានវិទ្យាបានដំណើរការជាធម្មតា តាមផែនការរបស់ថ្នាក់ដឹកនាំក្រសួង

-រៀបចំបង្កើត User Account ជូនមន្ត្រីរាជការសម្រាប់ប្រើប្រាស់ WiFi Internet នៅទីស្តីការក្រសួង

-រៀបចំបង្កើតសារអេឡិចត្រូនិច (Email) និងធ្វើសេចក្តីជូនដំណឹងផ្សព្វផ្សាយអំពីការរៀបចំសារអេឡិចត្រូនិច និងបោះពុម្ពនាមប័ណ្ណជូនមន្ត្រីរាជការ ។

### ១.២.ការងារបុគ្គលិក ៖

-បានធ្វើប្រកាសផ្ទេរក្របខ័ណ្ឌមន្ត្រីចំនួន០១នាក់ ទៅក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម

-បានធ្វើប្រកាសផ្ទេរភារកិច្ចជូនមន្ត្រីរាជការចំនួន០២នាក់

-បានធ្វើប្រកាសតែងតាំងជូនមន្ត្រីរាជការចំនួន០១នាក់

-បានធ្វើប្រកាសលុបឈ្មោះជូនមន្ត្រីរាជការចំនួន០៤នាក់

-បានធ្វើប្រកាសឲ្យឈប់ពិសេស ដើម្បីឈរឈ្មោះជាក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ចំនួន០៤នាក់

-បានធ្វើប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន០៤នាក់

-បានធ្វើប្រកាសជ្រើសរើសពលករអណ្តែតចំនួន៥២៩នាក់

-បានធ្វើប្រកាសជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន២៧៨នាក់

-បានបញ្ចូលប្រាក់មុខងារគ្រូគរុកោសល្យថ្មីចំនួន១១នាក់ ក្នុងតារាងទូទាត់បៀវត្ស

-បានបញ្ចូលប្រាក់ឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រី ក្នុងតារាងបៀវត្សចំនួន៣០៩នាក់

-មន្ត្រីចូលនិវត្តន៍មានចំនួន១២នាក់ (ថ្នាក់កណ្តាលចំនួន០៦នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន០៦នាក់) ។

**១.៣.ការងារនីតិកម្ម ៖**

-ចូលរួមប្រជុំអន្តរក្រសួង ស្តីពីគោលនយោបាយវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ចូលរួមប្រជុំពិនិត្យពិភាក្សាកិច្ចសន្យាផ្តល់សេវាកម្មឧបករណ៍មគ្គុទេសក៍ នៅសារមន្ទីរទួលស្លែង និងសារមន្ទីរជាតិភ្នំពេញ របស់ក្រុមហ៊ុន Narroweasters នៅទីស្តីការក្រសួង

-ចូលរួមប្រជុំពិភាក្សា ស្តីអំពីការពិនិត្យលើឯកសារនាំចេញវត្ថុសិល្បៈ ដែលព្រាងដោយនាយកដ្ឋានបុរាណវត្ថុ ។

**១.៤.ការងារគណនេយ្យ និងហិរញ្ញវត្ថុ ៖**

-ធ្វើសំណុំលិខិតសុំថវិការដ្ឋជំពូក៦០ និងជំពូក៦៤ សម្រាប់ប្រឡងជ្រើសរើសស្នាដៃតែងនិពន្ធប្រលោមលោក និងកំណាព្យរឿងឆ្នាំ២០១៤ និង សម្រាប់ប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មីចំនួន៧៩នាក់ ក្នុងឆ្នាំ២០១៤

-ធ្វើរបាយការណ៍ និងសាលាកប័ត្របង់ចំណូលចូលថវិការដ្ឋ ពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ ពីការត្រួតពិនិត្យវិស័យភាពយន្ត និងពីការត្រួតពិនិត្យវត្ថុសិល្បៈនាំចេញ-នាំចូល ប្រចាំខែមីនា ឆ្នាំ២០១៤

-ធ្វើសំណុំលិខិតសុំទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែមករា កុម្ភៈ ឆ្នាំ២០១៤

-ធ្វើលិខិតសុំថវិការដ្ឋចំណាយបេសកកម្មទៅក្រៅប្រទេសចំនួន០១លើក-សម្រាប់រៀបចំទទួលភ្ញៀវជាតិឆ្នាំ២០១៤-ទិញវត្ថុអនុស្សាវរីយ៍ជូនភ្ញៀវជាតិ និងអន្តរជាតិ ឆ្នាំ២០១៤-សម្រាប់ចំណាយរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងចំណាយធ្វើបង្គោលការពារស្ថានីយបុរាណ

-ធ្វើសំណុំលិខិតសុំថវិការដ្ឋចំណាយសិក្សាស្រាវជ្រាវស្ថានីយបុរាណក្នុងខេត្តរតនគីរី និងព្រះវិហារ ចំណាយបេសកកម្មក្នុងប្រទេស តាមបណ្តាខេត្តនានា និងចំណាយសិក្សាស្រាវជ្រាវ ចងក្រងឯកសារវត្ថុបុរាណ និងការប្រមូលវត្ថុបុរាណក្នុងខេត្តកំពង់ធំ និងស្ទឹងត្រែង យកមករក្សាទុក

-ធ្វើលិខិតអាណត្តិបើកប្រាក់សម្រាប់ចំណាយបេសកកម្មក្រៅប្រទេសចំនួន០២លើក

-ត្រួតពិនិត្យរបាយការណ៍តាមអាណត្តិនីមួយៗដែលបានចំណាយរួច

-ត្រួតពិនិត្យឯកសារបេសកកម្មដែលបានចុះរួចចំនួន១៥បេសកកម្ម

-ធ្វើសំណុំលិខិតរៀបចំគម្រោងចំណាយបេសកកម្មក្នុងប្រទេសចំនួន២០បេសកកម្ម

-រៀបចំធ្វើរដ្ឋទេយ្យជុំទី៣ និងទី៤ ។

**១.៥.ការងារសម្ភារៈ និងបរិក្ខារ ៖**

-ចុះទៅផ្ទៀងផ្ទាត់សៀវភៅ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៣ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង

-បានធ្វើសំណើសុំគោលការណ៍ធានាចំណាយ ដើម្បីថែទាំ និងជួសជុលរថយន្តឆ្នាំ២០១៤- ទិញវត្ថុអនុស្សាវរីយ៍ ជូនភ្ញៀវជាតិ និងអន្តរជាតិ ឆ្នាំ២០១៤-ចំណាយរៀបចំទទួលភ្ញៀវជាតិ សម្រាប់ឆ្នាំ២០១៤-ជួសជុលកែលម្អសារមន្ទីរខេត្តពោធិសាត់-ជួសជុលកែលម្អអាគារចាស់ៗ ក្នុងបរិវេណសាលាភូមិភាគ ស្រុកបាណន់ ខេត្តបាត់ដំបង-ជួសជុលកែលម្អបរិវេណសាលសន្និសីទចតុមុខ-ជួសជុលកែលម្អអាគារទីស្តីការ

ក្រសួង និងបន្ទប់ស្វូឌីយ៉ូ-ជួសជុលទល់ទ្រប្រាសាទភ្នំជីសូរ្យ ខេត្តតាកែវ និង ដើម្បីធ្វើការជួសជុល និងអភិរក្ស រូបចម្លាក់បុរាណ នៅក្នុងអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប

-បានធ្វើការបែងចែកសម្ភារៈការិយាល័យជូនថ្នាក់ដឹកនាំ និងគ្រប់នាយកដ្ឋាន និងបន្តបើកជូនសម្ភារៈការិយាល័យតាមការចាំបាច់ជូននាយកដ្ឋាននានា

-លើកគម្រោងជួសជុល កែលម្អសារមន្ទីរ នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិសាត់-កែលម្អអាគារចាស់ៗក្នុងបរិវេណសាលាភូមិភាគ នៅស្រុកបាណន់ ខេត្តបាត់ដំបង-កែលម្អបរិវេណជុំវិញសាលសន្និសីទចតុមុខ និង កែលម្អអាគារទីស្តីការក្រសួង និងបន្ទប់ស្វូឌីយ៉ូ

-អនុវត្តការងារដេញថ្លៃការផ្គត់ផ្គង់សម្ភារៈការិយាល័យ និងការបោះពុម្ពប្រចាំឆមាសទី១ ឆ្នាំ២០១៤

-អនុវត្តការងារពិគ្រោះថ្លៃការងារផ្គត់ផ្គង់សម្ភារៈសម្រាប់ថែទាំឧបករណ៍រថយន្ត

-អនុវត្តការងារពិគ្រោះថ្លៃការងារផ្គត់ផ្គង់ឧបករណ៍ភ្លេងបុរាណ

-អនុវត្តការងារពិគ្រោះថ្លៃការងារផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ប្រចាំឆ្នាំ២០១៤

-អនុវត្តការងារពិគ្រោះថ្លៃការងារផ្គត់ផ្គង់សម្ភារៈសម្រាប់ថែទាំអាគារ

-អនុវត្តការងារប្រគល់-ទទួលការងារផ្គត់ផ្គង់សម្ភារៈការិយាល័យឆមាសទី១ ឆ្នាំ២០១៤ ។

**១.៦.ការងារផែនការ ស្ថិតិ និងសរុប ៖**

-បន្តរៀបចំធ្វើតារាងសរុបស្តីពីគម្រោងវិនិយោគសាធារណៈដែលប្រើប្រាស់ថវិការដ្ឋ និងហិរញ្ញប្បទានផ្សេងៗរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ដែលក្រសួងបានទទួលក្នុងឆ្នាំ២០១៣

-បានសម្រេចការធ្វើរបាយការណ៍តាមរបបកំណត់ប្រចាំត្រីមាសទី១ ជូនគណៈរដ្ឋមន្ត្រី និងស្ថាប័នពាក់ព័ន្ធ

-បន្តរៀបចំធ្វើតារាងសរុបគម្រោងបញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈសម្រាប់ឆ្នាំ២០១៤-២០១៦។

**១.៧.ការងារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ៖**

បានចេញលិខិតបញ្ជាក់ការចុះបញ្ជីការពារស្នាដៃចំនួន០១ស្នាដៃ លិខិតអនុញ្ញាតការធ្វើអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតកសាសន៍ចំនួន២០បទ និង លិខិតអនុញ្ញាតបោះពុម្ពសៀវភៅចំនួន០១ស្នាដៃ។

**១.៨.ការងារសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ៖**

-បានទទួលលិខិតចូលចំនួន១៩ឯកសារ មកពីគ្រប់ស្ថាប័ន អង្គការ និងពីក្រៅប្រទេស ដើម្បីជូនថ្នាក់ដឹកនាំក្រសួងត្រួតពិនិត្យ និងសម្រេច

-គណៈប្រតិភូក្រសួងវប្បធម៌បានធ្វើទស្សនកិច្ចនៅក្រៅប្រទេសចំនួន០៧លើក ។

**១.៩.សាលាបណ្តុះបណ្តាលក្របខណ្ឌវប្បធម៌ ៖**

-បានរៀបចំឯកសារស្នើសុំគោលការណ៍បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការចំនួន០៣វគ្គគឺ៖ វគ្គបណ្តុះបណ្តាលការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម វគ្គបណ្តុះបណ្តាលការងាររដ្ឋបាល និងគ្រប់គ្រង និង វគ្គបណ្តុះបណ្តាលការងាររដ្ឋបាល និងបទពិសោធន៍ការងារសម្រាប់មន្ត្រីក្របខណ្ឌឆ្នាំ២០១៣

-បានរៀបចំឯកសារ បើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយនីតិវិធី និងវិធានការនៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដល់មន្ត្រីរាជការតាមអង្គភាព នាយកដ្ឋាន និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ។

## ២-ការងារបេតិកភណ្ឌរូបី ៖

### ២.១.ការងារគាំពារ និងអភិរក្សសំណង់បុរាណ ៖

**ក.ការងារអភិរក្សដ្ឋានអង្គរ ៖**

បន្តបោសសម្អាត និងដុះលាងរូបចម្លាក់ក្នុងឃ្លាំងរៀងរាល់សប្តាហ៍ ។

**ខ.ការងារការពារតំបន់ប្រាសាទ ៖**

-បានចុះទៅពិនិត្យ និងទប់ស្កាត់ប្រជាពលរដ្ឋកុំឲ្យសាងសង់លំនៅដ្ឋានថ្មីក្នុងតំបន់២ នៃប្រាសាទបន្ទាយឆ្មារ

-មន្ត្រីជំនាញចំនួន០១រូប ទៅចូលរួមសហការមិនអចិន្ត្រៃយ៍ជាមួយអង្គការ G.H.F ប្រចាំប្រាសាទបន្ទាយឆ្មារ

-បានរៀបចំឯកសារមួយចំនួន ដើម្បីសហការជាមួយអង្គការ UNESCO អំពីការរៀបចំប្លង់មេប្រាសាទបន្ទាយឆ្មារ ។

**គ.ការងារជួសជុលប្រាសាទ សំណង់បុរាណ ៖**

បានចុះពិនិត្យស្ថានភាពរោងទងទី៣ ផ្នែកខាងជើង ខាងកើត នៃប្រាសាទបន្ទាយឆ្មារ ដែលបានរលុះធ្លាក់ថ្ម ។

**ឃ.ការងារគ្រប់គ្រងសំណង់បុរាណ ៖**

បានស្រាវជ្រាវប្រមូលឯកសារប្លង់ពាក់ព័ន្ធនឹងប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ ពីសាលាបារាំងចុងបូព៌ា និង រាជបណ្ឌិតសភាកម្ពុជា ។

**ង.ការងារអភិរក្សតាមបណ្តាខេត្ត ៖**

<u>-អភិរក្សដ្ឋានកំពង់ធំ និង ព្រះវិហារ ៖</u>

+ចូលរួមសហការជាមួយអង្គការ Waseda ទាំងបច្ចេកទេសជួសជុល និងចងក្រងឯកសារការជួសជុលប្រាសាទសំបូរព្រៃគុក នៅខេត្តកំពង់ធំ ។

<u>-អភិរក្សដ្ឋានបាត់ដំបង បន្ទាយមានជ័យ និង ឧត្តរមានជ័យ ៖</u>

+ចូលរួមសហការជាមួយអង្គការ G.H.F ទាំងបច្ចេកទេសជួសជុល និងចងក្រងឯកសារការជួសជុលប្រាសាទបន្ទាយឆ្មារ នៅខេត្តបន្ទាយមានជ័យ ។

**ច.ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ ៖**

*កិច្ចសហការជាមួយអង្គការ G.H.F ជួសជុលប្រាសាទបន្ទាយឆ្មារ ៖

**ការងារជួសជុលរោងទងទី៣ ៖** រៀបថ្មជញ្ជាំងចំនួន៩១ដុំ-រៀបថ្មបាតជញ្ជាំងចំនួន០៥ដុំ-ដាក់ស្នូលថ្មភក់ថ្មីបាតជញ្ជាំងចំនួន០៥ដុំ-រៀបគ្រឹះថ្មបាយក្រៀមថ្មីបាតជញ្ជាំងខ្នាត ១១០ស.ម គុណ៥០ស.ម គុណ៤៥ស.ម ចំនួន១០ដុំ-រៀបគ្រឹះថ្មបាយក្រៀមថ្មីបាតថ្មកម្រាលខ្នាត១១០ស.ម គុណ៥០ស.ម គុណ៤៥ស.ម ចំនួន២៩ដុំ-រៀបថ្មកម្រាលចាស់ចំនួន៩៧ដុំ-រៀបថ្មសរសរធំ០២ដើម បានចំនួន០៧ដុំ-រៀបថ្មសរសរតូច០២ដើមបានចំនួន០៥ដុំ-រៀបថ្មខឿនក្រោយចំនួន២១ដុំ និងគូរប្លង់គ្រឹះថ្មបាយក្រៀមមើលពីលើបានចំនួន០៣ម៉ែត្រ។

**ការងារជួសជុលថ្ម ៖** ជួសជុលថ្មកម្រាលចំនួន១០ដុំ-ពុះថ្មបាយក្រៀមថ្មីចំនួន១២ដុំ និង ពុះថ្មភក់ថ្មី (ថ្មកម្រាល) ប្រវែង០២ម៉ែត្រ ចំនួន០១ដុំ ។

*កិច្ចសហការជាមួយអង្គការ Waseda ជួសជុលប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ ៖

**ការងារជួសជុលប្រាសាទ N1 ៖** ការជួសជុលបង្កាន់ដៃខាងត្បូងមុខខាងកើត ៖ បានរៀបបញ្ចូលឥដ្ឋថ្មីបាន១១ស្រទាប់ ពីស្រទាប់ទី១៩ ដល់ស្រទាប់ទី៣១-បានទាមដែកលើស្រទាប់ឥដ្ឋទី៧ និងនៅលើជញ្ជាំងនៅស្រទាប់ទី១១ ព្រមទាំងបានជួសជុលបង្កាន់ដៃខាងជើង នៃច្រកចូលខាងកើត ។

**២.២.ការងារសារមន្ទីរ ៖**

**ក.សារមន្ទីរជាតិភ្នំពេញ ៖**

-កំពុងចុះបញ្ជីកាតាឡុកសៀវភៅតាមប្រព័ន្ធកំព្យូទ័រ

-ការតាំងពិព័រណ៍ក្រៅប្រទេស ៖ យោងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសារមន្ទីរសិល្បៈមេត្រូប៉ូលីតាន សហរដ្ឋអាមេរិក រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឲ្យភាគីសហរដ្ឋអាមេរិក ខ្ចីវត្ថុសិល្បៈបុរាណខ្មែរចំនួន២០រូប យកទៅតាំងពិព័រណ៍នៅសារមន្ទីរមេត្រូប៉ូលីតាន សហរដ្ឋអាមេរិក រយៈពេល ៤ខែ (២៥.០៣.២០១៤ ដល់២០.០៧.២០១៤)។

-ការតាំងពិព័រណ៍ក្នុងប្រទេស ៖ នាយកដ្ឋានសារមន្ទីរ បានរៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី "ការរស់ឡើងវិញនូវប្រពៃណីត្បាញហូលពិតានខ្មែរ" រយៈពេល០៣ខែ (២៥.០១.២០១៤-២៧.០៤.២០១៤) នៅសារមន្ទីរជាតិកម្ពុជា

-ភ្ញៀវចូលទស្សនាសារមន្ទីរជាតិភ្នំពេញមានគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ភ្ញៀវជាតិ-អន្តរជាតិ សិក្ខាកាម សិស្ស និស្សិត ព្រះសង្ឃ សរុបមានចំនួន **១៩.២១៩នាក់** ក្នុងនោះមាន ៖

- ភ្ញៀវជាតិចំនួន **២.៤៥២ នាក់** ទទួលបានថវិកាចំនួន **៨៥៨.២០០រៀល**
- ភ្ញៀវអន្តរជាតិចំនួន **១៣.៨៨៧ នាក់** ទទួលបានថវិកា **៤៨.៦០៤ដុល្លាអាមេរិក**
- ភ្ញៀវចូលឥតបង់ថ្លៃចំនួន **២.៨៨០នាក់**

-ជួសជុលរូបចម្លាក់បាន**០៩រូប** ។

**ខ.សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ៖**

-ភ្ញៀវជាតិ-អន្តរជាតិ ព្រះសង្ឃ សិស្ស និស្សិតចូលទស្សនាចំនួន**៧.២៨៣នាក់** ក្នុងនោះភ្ញៀវអន្តរជាតិចំនួន**៧៤២នាក់**។

**គ.មណ្ឌលវត្តភ្នំ ៖**

-ភ្ញៀវទេសចរណ៍បរទេសចូលទស្សនាមានចំនួន**១០.២៩០នាក់** ។

**ឃ.មណ្ឌលជើងឯក ៖**

-ភ្ញៀវទេសចរណ៍បរទេសចូលទស្សនាមានចំនួន**១៩.១៨៧នាក់** ។

**២.៣.ការងារបុរាណវត្ថុ ៖**

-បានឆ្លងទម្រង់សាលាកប័ត្រចុះបញ្ជីសារពើភណ្ឌបុរាណវត្ថុក្រៅឃ្លាំង នៅអគ្គនាយកដ្ឋានបេតិកភណ្ឌ

-បានឆ្លងទម្រង់បែបបទ នៃការគ្រប់គ្រង និង ការផ្តល់សិទ្ធិឲ្យផ្នែកឯកជនក្នុងការនាំចេញវត្ថុសិល្បៈចេញទៅក្រៅប្រទេស នៅអគ្គនាយកដ្ឋានបេតិកភណ្ឌ

-ចុះពិនិត្យទីតាំងសម្រាប់ដាក់ផ្ទាំងប៉ាណូ ស្តីពីការទប់ស្កាត់ការបំផ្លិចបំផ្លាញ ការចរាចរ ការជួញដូរបុរាណវត្ថុខុសច្បាប់ បានចំនួន០៤កន្លែង នៅរាជធានីភ្នំពេញ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តស្វាយរៀង

-សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង និងកំពង់ធំ ស្រង់ព័ត៌មានវត្ថុបុរាណនៅក្រៅឃ្លាំង និងត្រៀមលក្ខណៈចុះបញ្ជីសារពើភណ្ឌ និងប្រមូលវត្ថុបុរាណនៅខេត្តទាំងពីរមករក្សាទុកនៅកន្លែងមានសុវត្ថិភាព

-ចុះពិនិត្យគម្រោងសាងសង់អាគារដាក់តាំងវត្ថុសិល្បៈ នៅសារមន្ទីរខេត្តព្រៃវែង

-**ការងារផ្តល់សេវាពិនិត្យវត្ថុសិល្បៈនាំចេញក្រៅប្រទេស** បានចំនួនសរុប**១.០៩០រូប** ទទួលថវិកាបានចំនួន**៦.១៩៥.០០០រៀល** ក្នុងនោះ ៖ វត្ថុសិល្បៈថ្មីចំនួន**១.០៥២រូប** ស្មើនឹង**៥.០១១.០០០រៀល** និងវត្ថុសិល្បៈចម្លងដូចចំនួន**៣៨រូប** ស្មើនឹង**១.១៣៤.០០០រៀល** ។

**៣-ការងារបេតិកភណ្ឌអរូបី ៖**

**៣.១.ការងារអត្តសញ្ញាណវប្បធម៌ ៖**

-បន្តរៀបចំផែនការស្រាវជ្រាវ និងចងក្រងឯកសារស្តីពីប្រពៃណី ទំនៀមទម្លាប់ នៃពិធីបុណ្យដារលាន

-សិក្សាពីពិធីបុណ្យសែនព្រេន និងពិធីរៀបអាពាហ៍ពិពាហ៍ របស់ជនជាតិក្រោល នៅខេត្តមណ្ឌលគីរី

-បន្តរៀបចំសារមន្ទីរខ្លែងខ្មែរ និង ពិព័រណ៍ជាតិពន្ធុ ដើម្បីបើកជូនមហាជនចូលទស្សនា និងសិក្សាស្រាវជ្រាវ ។

**៣.២.ការងារសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ៖**

-ថតវីដេអូឯកសារពីសកម្មភាពថ្នាក់ដឹកនាំ និងការងារអង្គភាពជុំវិញក្រសួងបាន០៤ចំណងជើង

-បានផ្តល់អាជ្ញាប័ណ្ណថ្មីសុំធ្វើអាជីវកម្មភាពយន្ត-វីដេអូចំនួន០១ផលិតកម្ម

-កាត់តតម្លើងរូបភាព បញ្ចូលសម្លេង និងផ្សព្វផ្សាយ បានចំនួន០២ឯកសារ

-ចុះបញ្ជីសុំផលិតវីដេអូខារ៉ាអូខេខ្មែរបាន០៤លេខ វីដេអូរឿងខ្មែរ (០១ដុំចប់) បាន០១ចំណងជើង វីដេអូរឿងភាគខ្មែរបាន០១ចំណងជើង និងសុំផលិតស្ប៉តខ្លីបាន០១ចំណងជើង

-ផ្តល់ទិដ្ឋាការខ្សែវីដេអូខារ៉ាអូខេខ្មែរបាន៣០លេខ

-ផ្តល់ទិដ្ឋាការខ្សែវីដេអូរឿងបរទេសបាន០៤ចំណងជើង និងចុះបញ្ជីកាស្សែតនាំចូលពីបរទេសបាន២៤ចំណងជើង។

-បានទទួលចំណូលពីការផ្តល់សេវាលើអាជីវកម្មភាពយន្ត-វីដេអូសរុបចំនួន**៦.៧២០.០០០រៀល** ដោយបង់ចូលថវិការដ្ឋ

-បានចុះពិនិត្យកន្លែងលក់ស៊ីឌី-វីស៊ីឌីគ្មានទិដ្ឋាការចំនួន០១លើក និងដកហូតបានឌីសគ្មានទិដ្ឋាការចំនួន៣៩០បន្ទះ និង១៤កេស ម៉ាស៊ីនថតចម្លង០៤គ្រឿង និងកំព្យូទ័រលើតុ០១គ្រឿង។ ចុះត្រួតពិនិត្យសមាគមន៍សិល្បៈភាពយន្តកម្ពុជា អំពីករណីរោងភាពយន្ត លេជេន ទួលគោក មិនទាន់មានច្បាប់អនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**៣.៣.ការងារសិល្បៈទស្សនីយភាព ៖**

-ការប្រគុំតន្ត្រី និងសម្តែងសិល្បៈ (មហាជន និងអាជីព) សរុបចំនួន៤៨៧លើក ក្នុងនោះនាយកដ្ឋានសិល្បៈសម្តែងក្នុងស្រុកបាន១៩លើក និងក្រៅប្រទេសបាន០២លើក

-បានហាត់សម និងតម្លើងស្នាដៃថ្មីចំនួន០២ស្នាដៃ

-លោកគ្រូ អ្នកគ្រូនៃនាយកដ្ឋានសិល្បៈទស្សនីយភាព បានចុះជួយបណ្តុះបណ្តាល និងពង្រឹងជំនាញសិល្បៈទស្សនីយភាព នៅតាមបណ្តាគ្រឹះស្ថានអប់រំ អង្គការ និង សមាគមន៍សិល្បៈនានារួមមាន ៖

+អ្នកគ្រូរបាំ និងចម្រៀងបុរាណ០៤រូប បង្ហាត់ នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

+សិល្បកររបាំប្រពៃណី០២រូប បង្ហាត់បច្ចេកទេសល្ខោនខោល នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

+លោកគ្រូ អ្នកគ្រូរបាំប្រពៃណី របាំបុរាណ និងល្ខោនចំនួន០៧នាក់ បង្ហាត់បង្រៀនសិស្សនៅសាលាមធ្យមវិចិត្រសិល្បៈ ។

**៣.៤.ការខារសៀវភៅ ការអាន ៖**

***បណ្ណាល័យជាតិ ៖**

-ភ្ញៀវជាតិ-អន្តរជាតិចូលអានមានចំនួន ៥៧៦នាក់

-បានទទួលសៀវភៅពីស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាល (សៀវភៅគ្រប់ភាសា) ចំនួន ២៩ក្បាល

-អ្នកសិក្សាស្រាវជ្រាវបានខ្ចីសៀវភៅយកទៅអានចំនួន១១៨ក្បាល

-ទទួលកាសែតចំនួន២១០ច្បាប់ និង ទស្សនាវដ្ដីផ្សេងៗ និងព្រឹត្តិបត្របរទេសចំនួន៧២ក្បាល

-បានចែកលេខ ISBN ដល់អ្នកបោះពុម្ពចំនួន៥៧លេខ

-ស្កេនសៀវភៅចាស់ចំនួន៧២ក្បាល និងបានបិទលេខកូដសៀវភៅចំនួន១៣៤ក្បាល

-ធ្វើកាតាឡុកទស្សនាវដ្ដីខ្មែរចំនួន១២ក្បាល

-ធ្វើកាតាឡុកសៀវភៅគ្រប់ប្រភេទជាភាសាខ្មែរ-បរទេសចំនួន៣០៤ក្បាល

-ធ្វើកាតាឡុកសៀវភៅចាស់ៗជាភាសាខ្មែរ-បរទេសចំនួន០៥ក្បាល ។

**៤.ការអភិវឌ្ឍធនធានមនុស្ស ៖**

**៤.១.សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**

*ឆ្នាំសិក្សា ២០១៣-២០១៤ មាននិស្សិតសរុបចំនួន**១.៦៦៤នាក់** (ស្រីចំនួន**៥០៩នាក់**) ក្នុងនោះ ៖

-និស្សិតអាហារូបករណ៍ចំនួន**៦០០នាក់** (ស្រីចំនួន**១៨៥នាក់**)

-និស្សិតបង់ថ្លៃសិក្សាចំនួន**១.០៦៤នាក់** (ស្រីចំនួន**៣២៤នាក់**)

-សាស្ត្រាចារ្យសរុបចំនួន២៩០នាក់ (ស្រីចំនួន៣៨នាក់)

-បន្តអនុវត្តកម្មវិធីសិក្សាឆមាសទី២ គ្រប់កម្រិតសិក្សា

-បើកការតាំងពិព័រណ៍ស្នាដៃ និងអនាគតរបស់និស្សិតសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងកម្មវិធីកំសាន្ត

-បន្តការជួសជុលអគារមហាវិទ្យាល័យបុរាណវិទ្យា

-សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានការវិវឌ្ឍន៍ និងដំណើរការបានយ៉ាងល្អប្រសើរ ដោយខិតខំបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយអង្គការ ស្ថាប័នអន្តរជាតិនានា សកលវិទ្យាល័យក្នុង និងក្រៅប្រទេស ពិសេសផ្ដោតលើការផ្ដល់អាហារូបករណ៍ដល់សាស្ត្រាចារ្យ និងនិស្សិតទៅបន្តការសិក្សានៅក្រៅប្រទេស និងការលើកកម្ពស់សមត្ថភាពភាសាបរទេសជូនមន្ត្រីរាជការ ។

**៤.២.សាលាមធ្យមវិចិត្រសិល្បៈ**

-ឆ្នាំសិក្សា២០១៣-២០១៤ សិស្សសិក្សានៅតាមសាលាជំនាញសរុបចំនួន **១.០២៧នាក់** ក្នុងនោះស្រី**៤៤៣នាក់**

-សិស្សស្នាក់នៅក្នុងសាលាមានចំនួន**១៩០នាក់** ក្នុងនោះស្រី**៦០នាក់**

-ប្រជុំគ្រូបច្ចេកទេស និងចំណេះទូទៅដើម្បីរៀបចំធ្វើការប្រឡងប្រចាំខែ

-រៀបចំអនុរក្សត្រួតពិនិត្យ និងស្រង់វត្តមានគ្រូ និងសិស្សទៅតាមសាលានីមួយៗ ។

**៥.ការងារអធិការដ្ឋាន ៖**

បានធ្វើអធិការកិច្ចនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ និងបាត់ដំបង ។

**៦.ការងារមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖**

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានរៀបចំថែរក្សាការពារសណ្តាប់ធ្នាប់ សោភ័ណភាព អនាម័យមណ្ឌលវត្តភ្នំបានល្អជាប្រចាំ ។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះត្រួតពិនិត្យទីតាំងជួល-លក់ស៊ីឌី វីស៊ីឌីចំនួន២៥លើក-កន្លែងលក់កាហ្វេបញ្ចាំងវីដេអូចំនួន២០លើក-អាជីវកម្មម៉ាស្សា កោសជប់ចំនួន០៥លើក-អាជីវកម្មអ៊ិនធើណេតចំនួន១៥លើក-អាជីវកម្មផ្តិតរូប ថតរូប ថតវីដេអូ ចំនួន០៧លើក និង ត្រួតពិនិត្យរោងភាពយន្តនៅផ្សារស៊ីធីម៉លចំនួន០១លើក ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ៖**

ការងារបេតិកភណ្ឌរូបី ៖ បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មន្ត្រីវប្បធម៌ស្រុក និង អាជ្ញាធរឃុំឈ្វាំង ស្រុកពញាឮ ចុះពិនិត្យស្ថានភាពខូចបែកបាក់ប្រាសាទស្រីគ្រប់ល័ក្ខណ៍នៅភ្នំប្រសិទ្ធិខាងជើង ដើម្បីស្នើសុំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជួយជួសជុល។ ចុះត្រួតពិនិត្យបង្គោលកំណត់ព្រំប្រទល់ស្ថានីយបុរាណ ដែលបានបោះរួច នៅទួលគុហាធំ ទួលកំណប់ និងទួលតាអ៊ុង ស្ថិតនៅឃុំសំពៅពូន ស្រុកកោះធំ ព្រមទាំងបានស្នើសុំព្រះសង្ឃ ប្រជាពលរដ្ឋកំពុងប្រើប្រាស់ទីទួល និងអាជ្ញាធរមូលដ្ឋានសហការគ្នាការពារបង្គោលទាំងនោះឲ្យបានស្ថិតស្ថេរ។ ការសាងសង់ក្លោងទ្វារចូលភ្នំព្រះរាជទ្រព្យសម្រេចបាន៧០ភាគរយ និង កំពុងបន្តឆ្លាក់រូបរឿងពុទ្ធប្រវត្តិតាមជញ្ជាំងព្រះវិហារធំបាន២០ផ្ទាំង ។

ការងារបេតិកភណ្ឌអរូបី ៖ បានដឹកនាំក្រុមសិល្បៈចេញសម្តែងក្នុងកម្មវិធីផ្សេងៗ និង បានថតចម្លងសៀវភៅក្បាច់ចម្លាក់ខ្មែរចំនួន២០ក្បាល ចែកជូនសិប្បករនៅក្រុងតាខ្មៅ ដើម្បីអនុវត្តត្រឹមត្រូវតាមក្បួនខ្នាត នៃក្បាច់ចម្លាក់ខ្មែរ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះទៅពិនិត្យវត្ថុបុរាណនៅប្រាសាទនាងខ្មៅបានចំនួន០១លើក និងសហការជាមួយក្រុមប្រឹក្សាឃុំកំពែង ចុះពិនិត្យការឈូសឆាយដីទួលបុរាណ នៅខាងលិចភូមិត្រពាំងអង្គ ចំនួន០១លើក។ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដែលរស់នៅជុំវិញតំបន់អង្គរបុរី មិនឲ្យសាងសង់លំនៅដ្ឋាននៅក្បែរប្រាសាទនានា ពីព្រោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រៀមដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន១០នាក់ និង សារមន្ទីរស្រុកអង្គរបុរីសរុបចំនួន៩៥នាក់ (អន្តរជាតិ១៥នាក់) ។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះត្រួតពិនិត្យអាជីវករជួល-លក់ឌីសគ្រប់ប្រភេទនៅក្រុងដូនកែវចំនួន០២លើក។ ចុះសិក្សាស្រាវជ្រាវអំពីសកម្មភាពតម្បាញហូលខ្មែរ នៅស្រុកបាទី ចំនួន០២លើក និងចុះត្រួតពិនិត្យសិប្បកម្មចម្លាក់អំពីស៊ីម៉ង់ត៍នៅស្រុកត្រាំកក់ ចំនួន០១លើក និងបានណែនាំដល់អាជីវករឲ្យអនុវត្តត្រឹមត្រូវតាមក្បួនខ្នាត នៃក្បាច់ចម្លាក់ខ្មែរ។ បានចុះសិក្សាអំពីក្បាច់គុនបុរាណខ្មែរ នៅស្រុកព្រៃកប្បាស ចំនួន០១លើក។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិសាត់ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះទៅត្រួតពិនិត្យទីតាំងថ្មបាយក្រៀម ស្ថិតនៅស្រុកភ្នំក្រវាញ បានចំនួន០១លើក ។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះត្រួតពិនិត្យស៊ីឌី-វីស៊ីឌីដែលគ្មានទិដ្ឋាការ និងតាមដានការចាក់បញ្ចាំងវីដេអូតាមហាងកាហ្វេចំនួន០២លើក។ បានចុះតាមការិយាល័យវប្បធម៌ស្រុក ជម្រុញអាជីវករដែលប្រកបអាជីវកម្មលើវិស័យវប្បធម៌ ដើម្បីមកសុំច្បាប់អនុញ្ញាតចំនួន០២លើក។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖**

ការងារបេតិកភណ្ឌរូបី ៖ បានទទួល និងជូននិស្សិតមកពីសកលវិទ្យាល័យន័រតុន មកធ្វើទស្សនកិច្ចនៅសារមន្ទីរខេត្ត សារមន្ទីរវត្តពោធិវាល និងសាលាខេត្ត។ បានសហការ និងផ្តល់ឯកសារពាក់ព័ន្ធនឹងទូលបុរាណ ដល់មន្ត្រីនគរបាល មកពីអគ្គនាយកដ្ឋានការពារបេតិកភណ្ឌ។ ភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន៣៦៦នាក់ (អន្តរជាតិចំនួន១២នាក់) ។

ការងារបេតិកភណ្ឌអរូបី ៖ បានហាត់ក្បាច់បាត ល្ខោន និងរបាំ ជាប្រចាំ។ បានអនុញ្ញាតច្បាប់អាជីវកម្មភាពយន្តបានចំនួន១៣ច្បាប់ និងអាជីវកម្មសិល្បៈសូនរូបចំនួន០៧ច្បាប់។ បណ្ណាល័យខេត្ត បានបើកទ្វារជូនសាធារណជនចូលអានសៀវភៅជារៀងរាល់ថ្ងៃ (លើកលែងថ្ងៃឈប់សម្រាក)។ ការិយាល័យច្រកចេញចូលតែមួយក្រុងបាត់ដំបង ចេញលិខិតអនុញ្ញាតគ្រប់សេវាកម្មវប្បធម៌ចំនួន០២ច្បាប់ និង នៅស្រុកបវេល ចេញលិខិតអនុញ្ញាតគ្រប់សេវាកម្មវប្បធម៌ចំនួន០១ច្បាប់ ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះពិនិត្យវត្ថុបុរាណក្នុងសារមន្ទីរខេត្ត និងសារមន្ទីរស្រុកស្វាយចេក។ ភ្ញៀវចូលទស្សនាប្រាសាទបន្ទាយឆ្មារសរុបចំនួន៥៩.២៣៦នាក់ និង សារមន្ទីរបុរាណវិទ្យាទេពកោសា-ស្វាយសរុបចំនួន២០នាក់ (អន្តរជាតិ០២នាក់) ។

ការងារបេតិកភណ្ឌអរូបី ៖ កំពុងបន្តរៀបចំចងក្រងឯកសារការងារបេតិកភណ្ឌអរូបី ផ្នែកសិល្បៈសូនរូប សិល្បៈទស្សនីយភាព សិល្បៈភាពយន្ត និងអភិវឌ្ឍវប្បធម៌បាន៥០ភាគរយ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះស្រង់ទិន្នន័យវត្ថុបុរាណដែលនៅរាយប៉ាយ និងនៅតំបន់ងាយរងគ្រោះ ក្នុងគម្រោងចុះប្រមូលវត្ថុបុរាណយកមករក្សាទុកនៅទីមានសុវត្ថិភាព និង ចុះស្រង់ស្ថិតិវត្ថុបុរាណនៅតាមបណ្តាទូល និងប្រាសាទបុរាណ ដើម្បីចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណ ។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះពិនិត្យអាជីវកម្មជួល-លក់ស៊ីឌី វីស៊ីឌី និងការបញ្ចាំងភាពយន្តវីដេអូតាមហាងកាហ្វេនៅក្រុងសំរោង និងស្រុកចុងកាល់ និង ចុះណែនាំអាជីវករជួលមេក្រូ ធុងបាស់ វីដេអូចល័ត អំពីកម្រិតសម្លេង នៅស្រុកបន្ទាយអំពិល។ ចុះពិនិត្យសកម្មភាពធ្វើពុម្ពរានទេព្តា នៅស្រុកអន្លង់វែង និងធ្វើពុម្ពស៊ីម៉ង់ត៍ នៅស្រុកបន្ទាយអំពិល ឲ្យគោរពតាមខ្នាតខ្មែរ។ បានចុះពិនិត្យទីតាំងលើកស្លាកសញ្ញាស្តីពីការទប់ស្កាត់ការចរាចរវត្ថុបុរាណខុសច្បាប់ នៅច្រកអូរស្មាច់ និងច្រកជាំស្រងាំ និងចុះពិនិត្យការដាក់តាំងស្លាកយីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្ម នៅស្រុកអន្លង់វែង។ ចុះពិនិត្យអាជីវកម្មអ៊ុតសក់ សម្អាងការ និងលម្អក្រចក នៅក្រុងសំរោង។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖**

ការងារបេតិកភណ្ឌរូបី ៖ ចុះស្រង់ព័ត៌មានវត្ថុបុរាណក្រៅឃ្លាំងចំនួន០៥លើក ដោយរកឃើញបំណែកចម្លាក់ថ្មបានចំនួន០៨ដុំ ស្ថិតនៅស្រុកសូទ្រនិគម និងចុះផ្សព្វផ្សាយសេចក្តីសម្រេចលេខ០១ ស.រ ស្តីពីការកំណត់បរិវេណប្រាសាទ ទួល ស្រះ ត្រពាំង និងស្ថានបុរាណ នៅស្រុកពួក និងស្រុកអង្គរជុំ ចំនួន ០២លើក ។

ការងារបេតិកភណ្ឌអរូបី ៖ បានផ្តល់លិខិតអនុញ្ញាតនាំចេញវត្ថុសិល្បៈចរាចរក្រៅប្រទេសចំនួន ០៥រូប។ បានចុះបង្ហាត់សិស្សសាលាសិល្បៈបុរាណខ្មែរ និងក្រុមសិល្បៈដែលគាំទ្រដោយអង្គការនានាបានចំនួន២៥ថ្ងៃ។ ចុះត្រួតពិនិត្យ ណែនាំការថតចម្លងលក់-ជួលឌីសគ្រប់ប្រភេទ និងការបញ្ចាំងភាពយន្ត ចាក់ធុងបាស់រាំកំសាន្តឱ្យចូលរួមអនុវត្តតាមលិខិតបទដ្ឋានច្បាប់ នៅក្រុងសៀមរាប ស្រុកពួក ស្រុកបន្ទាយស្រី និងស្រុកអង្គរជុំចំនួន១៣កន្លែង។ ចុះត្រួតពិនិត្យណែនាំកែលម្អដល់អាជីវករ-សិប្បករដែលកំពុងបម្រើសេវាកម្មទាក់ទងនឹងជំនាញសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម នៅក្រុងសៀមរាបចំនួន០៣លើក។ ចុះត្រួតពិនិត្យទីតាំងអាជីវកម្មលើកស្លាកយីហោថ្មីឱ្យអនុវត្តត្រឹមត្រូវតាមការណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅក្រុងសៀមរាប។ ចុះសហការជាមួយកម្លាំងចម្រុះថ្នាក់ខេត្ត មន្ទីរសាធារណៈការ និងសង្កាត់សាលាកម្រើក ចុះកាត់ទម្លាក់ស្លាកសញ្ញាចំនួន១២ស្លាក និងបដាចំនួន០៤ផ្ទាំង តាមដងស្ទឹងសៀមរាប។ ការិយាល័យច្រកចេញចូលតែមួយក្រុងសៀមរាប បានផ្តល់ច្បាប់បម្រើសេវាកម្មប្រគុំតន្ត្រីផ្សព្វផ្សាយផលិតផលចំនួន០៤ច្បាប់។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះទៅពិនិត្យទីតាំងប្រាសាទ ស្ថិតក្នុងដីក្រុមហ៊ុន រួយ ហ្វេង និងដាក់ស្លាកសញ្ញាតាមប្រាសាទនានា នៅស្រុកឆែប បានចំនួន០២លើក។ ចុះទៅពិនិត្យការកាប់ដើមឈើ តាមដងផ្លូវជាតិ របស់ក្រុមហ៊ុន Met Fone នៅក្នុងតំបន់ប្រាសាទព្រះលាន នៅស្រុកត្បែងមានជ័យ ចំនួន០១លើក។ សកម្មភាពឆ្មាំត្រួសត្រាយព្រៃបោសសម្អាតតាមប្រាសាទបុរាណសរុបចំនួន៣០,៥១០ម៉ែត្រការ៉េ។ ភ្ញៀវចូលទស្សនាប្រាសាទបាកានសរុបចំនួន៦២៨នាក់ (អន្តរជាតិ៣៩នាក់) និងប្រាសាទព្រះលានសរុបចំនួន៨៤នាក់ (អន្តរជាតិចំនួន១០នាក់) ។

ការងារបេតិកភណ្ឌអរូបី ៖ ក្រុមសិល្បៈបានចេញបម្រើក្នុងកម្មវិធីផ្សេងៗ និងបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះបញ្ជីវត្ថុបុរាណក្រៅឃ្លាំង នៅស្រុកស្ទោងបានចំនួន៩១ដុំ។ ទទួលភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនារមណីយដ្ឋានភ្នំសន្ទុកចំនួន១៦,០៤៧នាក់ (អន្តរជាតិ១០៤នាក់) ។ បានសហការជាមួយអង្គការ Waseda ជួសជុលបង្កាន់ដៃ N1 បានរួចរាល់ ។

ការងារបេតិកភណ្ឌអរូបី ៖ បានបន្តការហ្វឹកហាត់សិល្បៈដល់សិស្សថ្នាលរៀងរាល់ថ្ងៃអាទិត្យ។ ចុះជម្រុញដល់អាជីវករជួល-លក់ឌីសតាមបណ្តាស្រុកឲ្យមកធ្វើច្បាប់អាជីវកម្មឆ្នាំ២០១៤ ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះទៅសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ និងធ្វើកំណាយ នៅភូមិបាដើម ចំនួន០១កន្លែង និងភូមិហាងសាវ៉ាត់ចំនួន០១កន្លែង ស្ថិតនៅស្រុកសេសាន។ សហការជាមួយក្រុមការងារបុរាណវិទ្យា មកពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះធ្វើកំណាយ នៅភូមិអូរត្រែល និងភូមិកាំងតេជោ ស្ថិតនៅស្រុកថាឡាបរិវ៉ាត់ ។

ការងារបេតិកភណ្ឌអរូបី ៖ ក្រុមសិល្បៈបានចេញបម្រើក្នុងកម្មវិធីផ្សេងៗបានចំនួន០៥លើក ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគិរី ៖**

ការងារបេតិកភណ្ឌអរូបី ៖ បានហាត់រៀនបទភ្លេងរបាំ ប្រពៃណី និងមហោរីជាប់ជាប្រចាំ និងចុះទៅរំលឹករបាំតម្បាញឥសាន្ត ដល់ក្រុមសហគមន៍ភូមិពូតាំងចំនួន០១លើក។ ចុះបង្ហាត់ដល់ក្រុមសិស្សមណ្ឌលបុរីកុមារ ហាត់វាយឃ្មោះប្រាំមួយ (បទភ្លេងជនជាតិ) ចំនួន០៨លើក និង បង្ហាត់ដល់ក្រុមសិល្បៈសហគមន៍អង្គការលើកកម្ពស់សុខភាពជនជាតិដើមភាគតិច ឲ្យយល់ដឹងអំពីជម្ងឺអេដស៍ ចំនួន០៣លើក។ ចុះទៅពិនិត្យមជ្ឈមណ្ឌលវប្បធម៌ជនជាតិភ្នំដោះក្រមុំ ដោយបានចាត់កម្លាំងបោសសម្អាត នៅលើអាស្រមទាំងបី សម្រាប់ភ្ញៀវទេសចរណ៍មកចូលលេងកំសាន្ត។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖**

ការងារបេតិកភណ្ឌរូបី ៖ ចុះពិនិត្យប្រាសាទព្រៃដើមស្រុក នៅស្រុកស៊ីធរកណ្តាល ដើម្បីធ្វើការវាស់វែង និងស្នើសុំទៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបញ្ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ។ ចាក់ដីបន្ថែម និងកសាងស្ពានចូលបូជនីយដ្ឋានបារាយណ៍អណ្តែត ដែលជាអំណោយរបស់សប្បុរសជន។

ការងារបេតិកភណ្ឌអរូបី ៖ ចុះពិនិត្យអាជីវកម្មបញ្ចាំងវីដេអូលក់កាហ្វេចំនួន០១លើក នៅស្រុកកំពង់ត្របែក និងបានធ្វើកិច្ចសន្យាជាមួយអាជីវករ ដើម្បីឲ្យគោរពទៅតាមច្បាប់។ ចុះត្រួតពិនិត្យសិប្បកម្មពុម្ពស៊ីម៉ង់ត៍នៅស្រុពាមរក៍ និងស្រុកស្វាយអន្ទរចំនួន០២លើក។ បានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះពិនិត្យគម្រោងបង្កើតភូមិវប្បធម៌ នៅភ្នំតូច ស្រុកបាភ្នំ ដើម្បីកសាងរូបសំណាកនៅទីនោះ។

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖**

ការងារបេតិកភណ្ឌរូបី ៖ បានចុះត្រួតពិនិត្យទួលបុរាណ និងប្រាសាទបុរាណចំនួន២៧លើក និងចុះត្រួតពិនិត្យវត្ថុបុរាណនៅតាមទីសាធារណៈចំនួន០១លើក។ បានចុះសហការធ្វើប្លង់ទួលបុរាណបានចំនួន១៦ប្លង់ និងចុះផ្សព្វផ្សាយច្បាប់ ស្តីពីការការពារបេតិកភណ្ឌបានចំនួន០៤លើក ។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះបង្ហាត់របាំដល់សមាគមន៍យុវជនខេត្តចំនួន០១ក្រុម និងអង្គការកូដូខ្មែរ នៅឃុំតាសួសចំនួន០១ក្រុម។ បានចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ស៊ីឌី វីស៊ីឌីចំនួន១២លើក។ ចុះត្រួតពិនិត្យដល់សហគមន៍សិប្បកម្មអំពីឬស្សី និងអញ្ចូតចំនួន០១លើក និង ស្រាវជ្រាវ ចងក្រងប្រវត្តិអំពីសិប្បកម្មគ្រប់ប្រភេទបាន០១អត្ថបទ។ ចុះត្រួតពិនិត្យការដាក់តាំងស្លាកយីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្មចំនួន០៩លើក។ ចេញលិខិតអនុញ្ញាតលើកស្លាកសញ្ញា និងផ្ទាំងយីហោគ្រប់ប្រភេទចំនួន០៥កន្លែង និងចេញអាជ្ញាប័ណ្ណដល់អាជីវករក្នុងការប្រគុំ និងសម្តែងសិល្បៈចំនួន០៧លើក ។

**សេចក្តីសន្និដ្ឋាន ៖**

សកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងរយៈពេលមួយខែនេះ មានដំណើរការយ៉ាងសកម្មក្នុងកិច្ចថែរក្សា ការពារ លើកតម្កើងកេរតំណែលសម្បត្តិបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ទាំងនាយកដ្ឋាន

ជំនាញថ្នាក់កណ្តាល និង ថ្នាក់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ហើយយើងអាចវាយតម្លៃលើចំណុចមួយចំនួនមានជាអាទិ៍គឺ ៖

-ការងារគាំពារជួសជុលប្រាសាទបានដំណើរការគ្រប់ផ្នែកជំនាញក្នុងកិច្ចអភិរក្សជួសជុលប្រាសាទ និងចងក្រងឯកសារប្រវត្តិសាស្ត្រ

-នាយកដ្ឋានជំនាញ រួមសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត បានខិតខំបង្កើនការផ្សព្វផ្សាយសក្តានុពលវប្បធម៌ជាតិ ពង្រឹងការផ្តល់ និងបម្រើសេវាកម្មវប្បធម៌ដល់វិស័យឯកជន និងបានលើកទឹកចិត្តដល់ការបង្កើត និងបង្កើនផលិតកម្មសិប្បកម្មវប្បធម៌របស់វិស័យឯកជន ដោយធានាបានគុណភាព រក្សាបាននូវខ្នាតជាតិដើម្បីនិរន្តរភាពនៃការធ្វើអាជីវកម្ម និងទេសចរណ៍វប្បធម៌ ចូលរួមកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមពាក្យស្លោក "**វប្បធម៌ ជាសេដ្ឋកិច្ចជាតិ**" ជាក់ស្តែង នាយកដ្ឋានសារមន្ទីរ នាយកដ្ឋានបុរាណវត្ថុ នាយកដ្ឋានសិល្បៈភាពយន្ត នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នាយកដ្ឋានសៀវភៅ និងការអាន និងច្រកចេញចូលតែមួយដែលផ្តល់សេវាកម្មវប្បធម៌ នៃខេត្តសៀមរាប បាត់ដំបង កំពង់ឆ្នាំង និងខេត្តក្រចេះ មានដំណើរការជាប្រក្រតី ក្នុងការបម្រើសេវាកម្ម និងផ្តល់សេវាកម្មជូនភ្ញៀវទេសចរណ៍ និងអតិថិជន ដែលប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ។

**ទិសដៅប្រចាំខែ ឧសភា ឆ្នាំ២០១៤**

-បន្តត្រួតពិនិត្យ និងហាមឃាត់ប្រជាពលរដ្ឋដែលមកសាងសង់លំនៅដ្ឋានក្នុងតំបន់ប្រាសាទបន្ទាយឆ្មារ ដោយគ្មានការសុំច្បាប់ពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ G.H.F ជួសជុលប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យឱ្យបានល្អ

-បន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ Waseda ជួសជុលក្រុមប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំឱ្យបានល្អ

-ត្រៀមលើកគម្រោងជួសជុលប្រព័ន្ធធារាសាស្ត្រប្រាសាទបន្ទាយឆ្មារ ដែលស្ថិតក្នុងសភាពគ្រោះថ្នាក់បំផុត

-ត្រៀមធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន KIRI Travel ពីការងារបោះតង់ នៅប្រាសាទបន្ទាយឆ្មារ

-បន្តចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈនៅសារមន្ទីរជាតិ និងសារមន្ទីរខេត្ត

-បន្តចុះត្រួតពិនិត្យ និងផ្តល់ជំនួយបច្ចេកទេសអំពីការងារអភិរក្ស រៀបចំដាក់តាំងពិព័រណ៍ និងការចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ នៅសារមន្ទីរតាមខេត្ត

-ពិនិត្យឡើងវិញនូវការប្រមូលផ្តុំ និងចងក្រងជាសៀវភៅខ្នាតក្បាច់ចម្លាក់ភាគ២ លើកទី៣ មុននឹងបញ្ជូនឯកសារនេះជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច

-បន្តការស្រាវជ្រាវ និងការប្រមូលផ្តុំឯកសារស្រាវជ្រាវ ស្តីពីសម្ភារៈប្រើប្រាស់ប្រជាពលរដ្ឋខ្មែរភាគ៣ និងសៀវភៅក្បាច់ចម្លាក់ខ្មែរភាគ៣

-ធ្វើសេចក្តីព្រាងសារាចរ ស្តីពីវិធានការនៃការផលិតភាពយន្តបរទេស នៅកម្ពុជា

-រៀបចំកិច្ចដំណើរការបើកវគ្គបណ្តុះបណ្តាលអ្នកបច្ចេកទេសថតភាពយន្ត

-ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងសិល្បៈភាពយន្ត

-ត្រៀមសម្តែងសិល្បៈទស្សនីយភាពបម្រើព្រឹត្តិការណ៍សំខាន់ៗរបស់ជាតិ និងអន្តរជាតិ
-បន្តហាត់សម និងសិក្សាស្រាវជ្រាវសម្រាប់តម្លើងស្នាដៃសិល្បៈទស្សនីយភាព
-បន្តការជួសជុលអគារមហាវិទ្យាល័យបុរាណវិទ្យា ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

**រដ្ឋមន្ត្រី**

**ចម្លងជូន ៖**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ ទេសចរណ៍ ព្រឹទ្ធសភា
-គណៈកម្មការទី ៧ រដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី (នាយកដ្ឋានសរុប)
-ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)
-ក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ទីស្តីការគណៈរដ្ឋមន្ត្រី)
-ឯកសារ-កាលប្បវត្តិ